ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

នស/រកម/០៥៩៥/០២

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាម ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីប្រកាសបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀង ឥណទាន ចុះថ្ងៃ ទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥ រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់
## ស្តីពី
## ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទាន
## ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥
## រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី

### មាត្រា ១

ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានដែលរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ខ្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នូវទឹកប្រាក់ចំនួន ១៩.១៩៧.000 SDR (ដប់ប្រាំបួនលានមួយរយកៅសិបប្រាំពីរពាន់ អេស ឌី អរ) តាមឥណទានលេខ ១៣៤៥ CAM (SF) ដើម្បីបំរើគម្រោងការស្តារនិងអភិវឌ្ឍន៍អគ្គិសនី ។

### មាត្រា ២

ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ ១៩៩៥

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — **ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២
ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួង
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**